**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

សំណុំរឿងព្រហ្មទណ្ឌលេខ
៣៩៣ ចុះថ្ងៃទី០១.០៤.១៦
សំណុំរឿងជំនុំជម្រះលេខ
៩៧៦ ចុះថ្ងៃទី២៩.០៦.២០
សាលក្រមលេខ **៧៦ "ឌ"**
ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប សាលសវនាការលេខ២A

កាលបរិច្ឆេទបើកសវនាការ ថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹង ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ វេលារសៀល។

កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹង ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ វេលាព្រឹក។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ឋានៈជាចៅក្រម

### តំណាងអយ្យការ

លោកស្រី [redacted] ឋានៈជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១១០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ និងសំណុំរឿងជំនុំជម្រះលេខ ៣៣០ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **សារ៉ាត់** ភេទស្រី អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ ភូមិទី[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ ក្រុមទី៤ ភូមិ[redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ឆ្លើយ "ស" ម្តាយឈ្មោះ [redacted] ស៊ុត ប្តីឈ្មោះ [redacted] សោភ័ណ មានកូនចំនួន ០៣នាក់។

-ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៣៣៩ (ដ).ពស.ព្រទ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៩។

ត្រូវបានជាប់ចោទពីបទ ៖ **គម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ** ប្រព្រឹត្តនៅ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ។

## ភាគីដើមបណ្ដឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] **ម៉ិត** ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ ភូមិជ្រៃ ឃុំកណ្ដែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

- ដោយមានលោក [redacted] **ពល** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១២៥០/១៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។
- បានឃើញ ដីកាដំណោះស្រាយលេខ ៧៨៦៦ ពស.ព្រទ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។
- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៤៩៣ ពស.ព្រជ(ក) ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## អង្គហេតុកើតមានឡើងដូចតទៅ

កាលពីដើមឆ្នាំ២០១៨ នៅចំណុចភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប មានឈ្មោះ [redacted] ម៉ិត ជាជាងម៉ៅការសំណង់ បានម៉ៅការសាងសង់ផ្ទះឲ្យឈ្មោះ [redacted] សារ៉ាត់ ក្នុងតម្លៃ ៤៦.០០០ (សែសិបប្រាំមួយពាន់) ដុល្លារអាមេរិក ដែលសាងសង់ផ្ទះមានកម្ពស់ ២ជាន់ ០៦បន្ទប់ បណ្ដោយ ១៦ម៉ែត្រ គុណនឹង ៨.២ម៉ែត្រ បន្ទាប់ពីសាងសង់រួចឈ្មោះ [redacted] សារ៉ាត់ បានបើកប្រាក់ឲ្យទៅឈ្មោះ [redacted] ម៉ិត ខ្វះចំនួន ៣.០០០ (បីពាន់) ដុល្លារ ហើយឈ្មោះ [redacted] សារ៉ាត់ បានសន្យាឲ្យឈ្មោះ [redacted] ម៉ិត ទៅយកប្រាក់ដែលខ្វះក្នុងរយៈពេល ០១ខែកន្លះទៀត។ ដល់ពេលកំណត់ឈ្មោះ [redacted] ម៉ិត បានទៅយកប្រាក់ស្រាប់តែឈ្មោះ [redacted] សារ៉ាត់ មិនព្រមឲ្យហើយឈ្មោះនេះព្រមទាំងកូនប្រសារឈ្មោះ [redacted] ហឿយ , ឈ្មោះ [redacted] សុផាត និងឈ្មោះ [redacted] យុទ្ធ បានគម្រាមកំហែងឲ្យឈ្មោះ [redacted] ម៉ិត ធ្វើបង្កាន់ដៃផ្ទះបន្ថែមទៀតនៅជាន់ទី២ (មិនបានចែងក្នុងកិច្ចសន្យាទេ) បើមិនដូច្នេះទេពួកគេមិនបើកប្រាក់ដែលខ្វះនោះឲ្យទេ។

## សិទ្ធិនិយាយស្ដីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

- តំណាងអយ្យការបានសន្និដ្ឋានប្ដឹងសុំ ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ១២៥០/១៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្ដឹងសុំឲ្យចៅក្រមជំនុំជម្រះពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។
- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ៖ ស្នើសុំតុលាការពិនិត្យ និងសម្រេចឲ្យកូនក្ដីខ្ញុំបាទបានរួចផុតពីបទចោទប្រកាន់។ រឿងនេះជារឿងកិច្ចសន្យាសាងសង់ ហើយកូនក្ដីខ្ញុំបានឲ្យថ្លៃសាងសង់ផ្ទះនៅសល់តែចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកសម្រាប់ទូទាត់សំណង់ដែលដើមបណ្ដឹងសាងសង់ផ្ទះទៅលើគុណភាព។ ចំពោះការគម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ហាអ្វីមួយ តាមមាត្រា ៤២៤ គឺពុំមាននោះទេ។ សូមឲ្យតុលាការសម្រេចឲ្យកូនក្ដីខ្ញុំបាទរួចផុតពីបទចោទប្រកាន់ តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ផ្អែកតាមកិច្ចពិភាក្សាដេញដោល

- ក្រោយពីបានស្ដាប់ចម្លើយបដិសេធរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយបំភ្លឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់

# សំអាងហេតុ

- តាមរយៈដីកាដំណោះស្រាយលេខ ៧៨៦៦ ពស.ព្រទ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សារ៉ាត់** ទៅជំនុំជម្រះពីបទ ៖ **គម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ** ប្រព្រឹត្តនៅ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ។

- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **សារ៉ាត់** បានឆ្លើយថា ៖ ខ្លួនមិនបានប្រព្រឹត្តបទៈគម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ ទៅលើឈ្មោះ [redacted] ម៉ិត នោះទេ។ នៅឆ្នាំ២០១៨ ខ្លួនបានចុះកិច្ចសន្យាសាងសង់ផ្ទះជាមួយនឹងឈ្មោះ [redacted] ម៉ិត មែន ដោយឲ្យឈ្មោះ [redacted] ស័ក្តិ ជាអ្នកទទួលម៉ៅការ រីឯឈ្មោះ [redacted] ម៉ិត ជាជាងសាងសង់។ ផ្ទះបានធ្វើរួចរាល់អស់ហើយ ប៉ុន្តែមានបន្ទប់ខ្លះមានការជ្រាបទឹក និងមានការប្រេះជញ្ជាំង។ ពេលនោះខ្លួនបានឲ្យឈ្មោះ [redacted] ម៉ិត មកជួសជុលឲ្យខ្លួន តែឈ្មោះ [redacted] ម៉ិត ពុំបានមកជួសជុលឲ្យខ្លួនទេ ទើបខ្លួនមិនព្រមប្រគល់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារ ទៅឲ្យឈ្មោះ [redacted] ម៉ិត។ ខ្លួននៅជំពាក់ឈ្មោះ ស៊ិម ម៉ិត តែចំនួន ១.០០០ (មួយពាន់) ដុល្លារ។

- ពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ម៉ិត** (អវត្តមាន) តែតាមអំណានចម្លើយនៅជំណាក់កាលអយ្យការបានឆ្លើយបំភ្លឺថា ៖ ខ្លួនបានម៉ៅការសាងសង់ផ្ទះឲ្យឈ្មោះ [redacted] សារ៉ាត់ ក្នុងតម្លៃ ៤៦.០០០ (សែសិបប្រាំមួយពាន់) ដុល្លារអាមេរិក ដែលប្រាក់នោះម្ចាស់ផ្ទះបានបើកទៅឲ្យឈ្មោះ [redacted] ស័ក្តិ អស់ចំនួន ៣៣.៥០០ (សាមសិបបីពាន់ប្រាំរយ) ដុល្លារអាមេរិក ដែលឈ្មោះ [redacted] ស័ក្តិ ជាអ្នកណែនាំខ្លួនឲ្យមកសាងសង់ផ្ទះរបស់ឈ្មោះ [redacted] សារ៉ាត់ តែក្រោយមកឈ្មោះ [redacted] ស័ក្តិ មានទំនាស់ជាមួយម្ចាស់ផ្ទះឈ្មោះ ណាម សារ៉ាត់ និងកូនទាំង ០៣របស់គេ ទើបឈ្មោះ [redacted] ស័ក្តិ ឈប់ធ្វើ ហើយការសាងសង់នោះខ្លួនជាអ្នករ៉ាប់រងទាំងអស់។ បន្ទាប់មកឈ្មោះ [redacted] សារ៉ាត់ បានប្រាប់ខ្លួនថាគេបានឲ្យប្រាក់ទៅឈ្មោះ [redacted] ស័ក្តិ អស់ចំនួន ៣៧.៥០០ (សាមសិបប្រាំពីរពាន់ប្រាំរយ) តែការពិតឲ្យអស់ត្រឹមតែ ៣៣.៥០០ (សាមសិបបីពាន់ប្រាំរយ) ដុល្លារអាមេរិក តែប៉ុណ្ណោះ។ ក្រោយមកនៅអំឡុងពេលដែលខ្លួនសាងសង់ផ្ទះនោះជាបន្តបន្ទាប់ខ្លួនបានបើកប្រាក់ពីឈ្មោះ [redacted] សារ៉ាត់ នៅសល់តែ ១.០០០ ដុល្លារ ទៀតប៉ុណ្ណោះ ប៉ុន្តែលើកមុនម្ចាស់ផ្ទះបានបូកលុយខ្លួនលើសចំនួន ២.០០០ ដុល្លារទៀតសរុបទាំងអស់ដែលម្ចាស់ផ្ទះនៅជំពាក់ខ្លួនគឺ ៣.០០០ ដុល្លារ បន្ថែមទៀត។ ពេលដែលខ្លួនទៅយកលុយនោះស្រាប់តែម្ចាស់ផ្ទះឈ្មោះ [redacted] សារ៉ាត់ បានប្រាប់ថាបើចង់បានលុយត្រូវធ្វើជណ្តើរផ្ទះរបស់ខ្លួននៅជាន់ទី២បន្ថែមទៀត ដែលមិនមែនជាកាតព្វកិច្ចរបស់ខ្លួនព្រោះមិនបានចែងនៅក្នុងកិច្ចសន្យាទេ តែដោយសារតែខ្លួនខ្លាចគេមិនបើកលុយឲ្យទើបខ្លួនបានបង្ខំចិត្តធ្វើជណ្តើរឲ្យគេបន្តទៀតដែលមានតម្លៃ ១.៥០០ ដុល្លារ បន្ថែមទៀត។ ដូចនេះ ប្រាក់ដែលឈ្មោះ [redacted] សារ៉ាត់ ជំពាក់ខ្លួនសរុបចំនួន ៤.៥០០ ដុល្លារ។

- តាមចម្លើយរបស់ឈ្មោះ [redacted] **ម៉ិត** ជាដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ខ្លួនជាអ្នកម៉ៅការសំណង់ឲ្យម្ចាស់ផ្ទះឈ្មោះ [redacted] សារ៉ាត់ ហើយនៅពេលដែលខ្លួនបានសាងសង់ផ្ទះរួចរាល់ហើយគឺខ្លួនបានទៅសុំបើកលុយដែលនៅសល់ ប៉ុន្តែម្ចាស់ផ្ទះមិនព្រមបើកឲ្យ ថែមទាំងឲ្យខ្លួនសាងសង់បន្ថែម ទើបបើកលុយឲ្យ។ ប៉ុន្តែជនជាប់ចោទបានឆ្លើយបដិសេធថា ខ្លួនមិនបានគម្រាមកំហែងទៅលើដើមបណ្តឹងរដ្ឋប្បវេណីនោះទេ គឺខ្លួនគ្រាន់តែបានឲ្យឈ្មោះ [redacted] ម៉ិត ធ្វើការជួសជុលនៅកន្លែងដែលមានការខូចខាតតែប៉ុណ្ណោះ។

- តាមការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា មិនមានភស្តុតាងដែលបញ្ជាក់ឲ្យឃើញថាពិតជានៃអំពើបង្កើតជាបទល្មើសណាមួយ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទឡើយ ហើយ[illegible]



Scanned with CamScanner

មានជាភស្តុតាងនោះក៏មិនអាចបង្ហាញឲ្យឃើញពីអំពើ នៃការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទដែរ។ ចំណែកតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយបំភ្លឺនៅដំណាក់កាលអយ្យការ ក៏មិនបង្ហាញឲ្យឃើញពីអត្ថិភាពនៃបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទឡើយ។

- ផ្អែកតាមសំអាងហេតុខាងលើនេះ តុលាការយល់ឃើញថា មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សារ៉ាត់** នោះទេ ដោយហេតុថាអង្គហេតុ និងភស្តុតាងដាក់បន្ទុក មិនអាចសបញ្ជាក់ឲ្យឃើញថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើសណាមួយដែលជាកំហុស ដើម្បីតុលាការប្រកាសពីពិរុទ្ធភាព ស្របតាមបញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះទេ។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ១២៥០/១៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ឃើញថាការប្តឹងសុំនេះមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះទេ ដោយហេតុថាការចោទប្រកាន់មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីតុលាការប្រកាសពីពិរុទ្ធភាពរបស់ជនជាប់ចោទស្របតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ដែលបានស្នើសុំ ៖ តុលាការនឹងពិនិត្យពិចារណាសម្រេចតាមច្បាប់។

- ផ្អែកតាមសំអាងហេតុខាងលើនេះ ឃើញថាមិនមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សារ៉ាត់** ពីបទ ៖ **គម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ** ប្រព្រឹត្តនៅ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ នោះទេ គប្បីតុលាការសម្រេចឲ្យជនជាប់ចោទ រួចខ្លួនពីបទចោទ ស្របតាមបញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**ក្រោយពីបានពិនិត្យពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថា ៖**</u>

- មិនមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សារ៉ាត់** ពីបទ ៖ **គម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ** ប្រព្រឹត្តនៅ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ នោះទេ ដោយហេតុថាអង្គហេតុ និងភស្តុតាងដាក់បន្ទុកមិនអាចសបញ្ជាក់ឲ្យឃើញថាជនជាប់ចោទទាំងអស់ ពិតជាបានប្រព្រឹត្តបទល្មើសណាមួយដែលជាកំហុស ដើម្បីតុលាការប្រកាសពីពិរុទ្ធភាព ស្របតាមបញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះទេ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **មុិត** ប្តឹងទាមទារសំណងជាទឹកប្រាក់ចំនួន **៤.៧០០ (បួនពាន់ប្រាំពីររយ) ដុល្លារអាមេរិក** និងសំណងជម្ងឺចិត្តជាទឹកប្រាក់ចំនួន **១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារអាមេរិក** គប្បីតុលាការបដិសេធចោល។

<u>**សាលាដំបូងខេត្តសៀមរាប**</u>

<u>**វិនិច្ឆ័យសេចក្តី**</u>

**១- ឲ្យជនជាប់ចោទ ៖**

-ឈ្មោះ [redacted] **សារ៉ាត់** ភេទស្រី អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ ក្រុមទី៤ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក

ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ឆ្លើយ "ស" ម្ដាយឈ្មោះ [redacted]ស៊ុត "ស" ប្ដីឈ្មោះ [redacted]សោភ័ណ មានកូនចំនួន ០៣នាក់ (ក្រៅឃុំ)។

រួចខ្លួនពីបទចោទ ពីបទ ៖ **គម្រាមកំហែងថានឹងធ្វើឲ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ** ប្រព្រឹត្តនៅ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ។

២- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ តែកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

- ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ

ថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅសៀមរាប, ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅសៀមរាប ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner